**BOSTON REGION METROPOLITAN PLANNING ORGANIZATION**

Stephanie Pollack, MassDOT Secretary and CEO and MPO Chair
Karl H. Quackenbush, Executive Director, MPO Staff

# នីតិវិធីនៃការដាក់ពាក្យបណ្តឹង

State Transportation Building • Ten Park Plaza, Suite 2150 • Boston, MA 02116-3968
Tel. (857) 702-3700 • Fax (617) 570-9192 • TTY (617) 570-9193 • www.bostonmpo.org

**<u>សេចក្តីផ្តើម</u>**

ជំពូកនេះរៀបរាប់ពីនីតិវិធីដែលម៉ាសដុត (MassDOT) អនុវត្ត និងសម្រេចពាក្យបណ្តឹងស្តីពីការរើសអើងមាត្រាទី6។ នីតិវិធីទាំងនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ចំណាត់ការស្របច្បាប់អោយដើមបណ្តឹង និងចុងបណ្តឹង។ ខ្លឹមសារនីតិវិធីទាំងនេះត្រូវបានកែសម្រួលក្នុងឆ្នាំ2017 ដែលជាផ្នែកមួយនៃកិច្ចសហការរវាងអង្គភាពមាត្រាទី6 នៃODCR និងក្រុមស៊ើបអង្កេត។ ក្នុងស្មារតីឯកភាព និងតម្លាភាព បុគ្គលិកODCR បានខិតខំប្រឹងប្រែងធ្វើអោយនីតិវិធីនៃការដាក់ពាក្យបណ្តឹងនៅគ្រប់ផ្នែករបស់រដ្ឋនិងសហព័ន្ធដែលតម្រូវអោយគ្មានការរើសអើង (ដូចជាមាត្រាទី6 និងទី7) មានភាពដូចគ្នា អាចធ្វើទៅបាន ហើយសាធារណជនអាចយល់បានដោយងាយស្រួល។

**<u>គោលបំណង និង ការអនុវត្ត</u>**

ជំពូកនេះចងក្រងឡើង ដើម្បីបង្កើតនីតិវិធីសម្រាប់អនុវត្ត និងធ្វើការសម្រេច ទាំងពាក្យបណ្តឹងស្តីពីការរើសអើងដែលគេប្តឹងមក MassDOT ដោយផ្ទាល់ និងពាក្យបណ្តឹងស្តីពីការរើសអើងដែល MassDOT មានសិទ្ធអំណាចចាត់ចែងក្រោមមាត្រាទី6 នៃច្បាប់ស្តីពីសិទ្ធស៊ីវិលឆ្នាំ 1964 (the Civil Rights Act of 1964) ហើយនិងអាជ្ញាធររដ្ឋ និងអាជ្ញាធរសហព័ន្ធផ្នែកគ្មានការរើសអើង រួមទាំង ច្បាប់ស្តីពី ជនពិការជនជាតិអាមេរិក (ADA)។

នីតិវិធីទាំងនេះរៀបរាប់ពីដំណើរការរដ្ឋបាលដែលមានគោលដៅកំណត់សម្គាល់ និងលុបបំបាត់ការរើសអើងក្នុងសកម្មភាពនិងកម្មវិធីនានាដែលសហព័ន្ធផ្តល់ជំនួយ។ នីតិវិធីទាំងនេះមិនផ្តល់មធ្យោបាយដោះស្រាយដល់ដើមបណ្តឹងដែលស្វែងរកការព្យាបាលផ្ទាល់ខ្លួន រួមមានការសងជម្ងឺចិត្ត ឬប្រាក់ទូទាត់នោះទេ។ នីតិវិធីទាំងនេះក៏មិនហាមឃាត់ដើមបណ្តឹងមិនអោយទៅដាក់ពាក្យប្តឹងជាមួយនឹងភ្នាក់ងាររដ្ឋ និងសហព័ន្ធផ្សេងទៀត ឬក៏បដិសេធសិទ្ធរបស់ដើមបណ្តឹងក្នុងការស្នើសុំការផ្តល់ប្រឹក្សាជាលក្ខណៈឯកជនសម្រាប់ដោះស្រាយទង្វើរើសអើងដែលបានចោទក្នុងពាក្យបណ្តឹងនោះដែរ។

នីតិវិធីដែលបានរៀបរាប់ក្នុងឯកសារនេះត្រូវបានគេអនុវត្តជាមួយនឹង MassDOT ហើយនិងអ្នកទទួលជំនួយបន្ត ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត រាល់ការគ្រប់គ្រងសកម្មភាពនិងកម្មវិធីនានាដែលសហព័ន្ធផ្តល់ជំនួយ។

ជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងរបស់ពួកគេក្នុងការអនុវត្តតាមមាត្រាទី6 អ្នកដែលទទួលជំនួយហិរញ្ញវត្ថុពីសហព័ន្ធតាមរយៈ MassDOT ត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់នីតិវិធីនៃការដាក់ពាក្យបណ្តឹងនេះ។ ការប្រើប្រាស់នីតិវិធីនេះបញ្ជាក់ថាអ្នកទទួលជំនួយបន្តទាំងនេះ ទទួលស្គាល់កាតព្វកិច្ចរបស់ពួកគេក្នុងការផ្តល់ឱកាសអោយសាធារណជនដាក់ពាក្យបណ្តឹងប្រឆាំងនឹងការបំពានលក្ខខណ្ឌគ្មានការរើសអើង គ្រប់សកម្មភាព សេវាកម្ម និងកម្មវិធីនានារបស់អង្គភាព។ ស្របតាមការណែនាំរបស់សហព័ន្ធ អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរ យល់ដឹងថាពួកគេមានសិទ្ធអំណាចក្នុងការអនុវត្តបណ្តឹងមាត្រាទី6 រួចផ្តល់ដំណឹងដល់អ្នកទទួលជំនួយដែលជា MassDOT អំពីពាក្យបណ្តឹងដែលគេបានទទួល និង លទ្ធផលនៃការស៊ើបអង្កេតនៅពេលដែលដោះស្រាយពាក្យបណ្តឹង។ អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរលើផ្លូវធំ កាន់តែយល់ថា ពួកគេគ្មានសិទ្ធអំណាចក្នុងការស៊ើបអង្កេត ពាក្យបណ្តឹងស្តីពីបទល្មើសមាត្រាទី6 ដែលមានអង្គភាពរបស់ពួកគេជាចុងបណ្តឹងនោះទេ (ប្រសិនអង្គភាពរបស់ពួកគេជាចុងបណ្តឹង ឬ ភាគីដែលត្រូវបានគេចោទថាបានល្មើសមាត្រាទី6) ។ គ្រប់ពាក្យបណ្តឹងទាំងនេះ នឹងត្រូវគេបញ្ជូនទៅ MassDOT ដើម្បីធ្វើការសម្រេចថា អង្គភាពណាមានសិទ្ធស៊ើបអង្កេត។ អ្នកទទួលជំនួយបន្តទាក់ទងនឹងការធ្វើដំណើរលើផ្លូវធំ រក្សាសិទ្ធពិចារណាថាការចោទប្រកាន់នៃការល្មើសមាត្រាទី6 ជាបញ្ហារ៉ាប់រង និង/ឬ បញ្ហានៃការគោរពគោលការណ៍ផ្ទៃក្នុង ប៉ុន្តែពួកគេត្រូវបានហាមឃាត់មិនអោយចេញសេចក្តីសម្រេច ព្រោះនេះអាចជាការល្មើសមាត្រាទី6។ MassDOT សូមលើកទឹកចិត្តអោយអ្នកទទួលជំនួយបន្តទាំងអស់ទាក់ទងទៅអ្នកជំនាញមាត្រាទី6 របស់ ODCR ដែលជានាយកគ្រប់គ្រងកម្មវិធីសហព័ន្ធ និង/ឬ នាយកគ្រប់គ្រងស៊ើបអង្កេត នៅពេលដែល/ប្រសិនបើពួកគេបានទទួលពាក្យបណ្តឹងទាក់ទងនឹងមាត្រទី6 ដើម្បីធានាថាមានការដោះស្រាយត្រឹមត្រូវ។

**<u>និយមន័យ</u>**

*ដើមបណ្តឹង (Complainant )*៖ ជនណាដែលដាក់ពាក្យបណ្តឹងទៅ MassDOT។

*ពាក្យបណ្តឹង (Complaint)*៖ ឯកសារស្តីពីការចោទប្រកាន់ទាក់ទងនឹងការរើសអើង ជាលិខិតសរសេរដោយដៃ ឬ ជាសារអេឡិចត្រូនិចដែលទាមទារអោយការិយាល័យដែលបានទទួលឯកសារនោះចាត់វិធានការដោះស្រាយ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងមានពិការភាព នោះនិយមន័យនៃពាក្យបណ្តឹងនេះ រាប់បញ្ចូលទាំងទម្រង់ផ្សេងៗដែលជួយសម្រួលដល់ពិការភាពរបស់ដើមបណ្តឹង។

*ការរើសអើង (Discrimination)*៖ សកម្មភាព ឬ អសកម្មភាព ដោយចេតនា ឬ អចេតនា ចំពោះជនណាម្នាក់ក្នុងសហរដ្ឋអាមេរិកដែលបានទទួលរងភាពមិនស្មើគ្នា ឬ ភាពខុសគ្នាដាច់ស្រឡះក្នុងសកម្មភាពឬកម្មវិធីណាមួយដែលសហព័ន្ធផ្តល់ជំនួយ ដោយសារតែជាតិសាសន៍, ពណ៌សម្បុរ ដើមកំណើត ឬលក្ខណៈផ្សេងទៀតដែលទទួលស្គាល់ដោយអាជ្ញាធរគ្មានការរើសអើងដូចជា ភេទ អាយុ ឬពិការភាព។

*រដ្ឋបាលប្រត្តិបត្តិការ (Operating Administrations)*៖ ភ្នាក់ងារផ្សេងៗនៃនាយកដ្ឋានដឹកជញ្ជូនរបស់សហរដ្ឋអាមេរិក រួមមាន រដ្ឋបាលផ្លូវធំរបស់សហព័ន្ធ *(Federal Highway Administration) (FHWA)* រដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ *(Federal Transit Administration) (FTA)* រដ្ឋបាលផ្លូវដែករបស់សហព័ន្ធ *(Federal Rail Administration)* និងរដ្ឋបាលសុវត្ថិភាពចរាចរណ៍ផ្លូវជាតិ *(National Highway Traffic Safety Administration) (NHTSA)* ដែលផ្តល់ជំនួយអោយសកម្មភាព ឬកម្មវិធីទាំងឡាយណាទាក់ទងនឹងការដឹកជញ្ជូន។

*ចុងបណ្តឹង (Respondent)*៖ ជនណា, ភ្នាក់ងារណា, ស្ថាប័នណា, ឬ អង្គការណាដែលត្រូវបានគេចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធនឹងការរើសអើង។

**<u>ការដាក់ពាក្យបណ្តឹង</u>**

ផ្នែកនេះនឹងរៀបរាប់លម្អិតអំពីនីតិវិធីរបស់នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាស្សាឈូសេត *(*MassDOT*)* ក្នុងការចាត់ចែងពាក្យបណ្តឹងស្តីពីការរើសអើងមាត្រាទី*6* (រើសអើងដោយសារជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត រួមបញ្ចូលទាំងភាសា) និង ពាក្យបណ្តឹងស្តីពីការរើសអើងដែលមានចែងបន្ថែមក្នុងច្បាប់ស្តីពីភាពគ្មានការរើសអើងរបស់សហព័ន្ធ (រើសអើងដោយសារ ភេទ អាយុ ឬពិការភាព)។ ច្បាប់និងនីតិបញ្ញត្តិរបស់សហព័ន្ធដែលគ្របដណ្តប់មាត្រាទី*6* នៃច្បាប់ស្តីពីសិទ្ធស៊ីវិលឆ្នាំ*1964* (មាត្រាទី *6*) ផ្តល់សិទ្ធអំណាចសម្របសម្រួលក្នុងការស៊ើបអង្កេតពាក្យបណ្តឹងទាក់ទងនឹងសិទ្ធស៊ីវិលទៅអោយនាយកដ្ឋានយុត្តិធម៌សហរដ្ឋអាមេរិក (US DOT) ដែលសហការយ៉ាងជិតស្និតជាមួយនិងភ្នាក់ងារសហព័ន្ធដែលមានទំនួលខុសត្រូវនេះ។ ក្នុងវិស័យដឹកជញ្ជូន សិទ្ធអំណាចស៊ើបអង្កេតនេះស្ថិតក្នុងដៃនាយកដ្ឋានដឹកជញ្ជូនសហរដ្ឋអាមេរិក *(US DOT)* និងភ្នាក់ងារផ្សេងៗរបស់នាយកដ្ឋាននេះសម្រាប់មធ្យោបាយដឹកជញ្ជូនផ្សេងៗ រួមទាំងរដ្ឋបាលផ្លូវធំរបស់សហព័ន្ធ *(*FHWA) និងរដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ *(FTA)*។ ដើម្បីអោយស្របទៅតាមលក្ខខណ្ឌរបស់នាយកដ្ឋានដឹកជញ្ជូនសហរដ្ឋអាមេរិក FHWA និងFTA បានបង្កើតបទបញ្ញត្តិ និងការណែនាំ ដែលតម្រូវអោយអ្នកទទួលជំនួយ និងអ្នកទទួលជំនួយសហព័ន្ធបន្ត បង្កើតនីតិវិធីសំរាប់ចាត់ចែងពាក្យបណ្តឹងមាត្រាទី*6* ដែលគេបានដាក់ជាមួយនឹងអង្គភាពទាំងនេះ។

នីតិវិធីដែលមានរៀបរាប់ខាងក្រោម ត្រូវបានកែសម្រួលពីនីតិវិធីដែលត្រូវបានណែនាំអោយប្រើប្រាស់ ដោយនាយកដ្ឋានយុត្តិធម៌សហរដ្ឋអាមេរិក *(US DOJ)* ហើយត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឱកាសស្មើភាពមួយ ក្នុងការដោះស្រាយពាក្យបណ្តឹងដែលគោរពតាមនីតិវិធីត្រឹមត្រូវ អោយទាំងដើមបណ្តឹង និងចុងបណ្តឹង។ ក្រៅពីនីតិវិធីដោះស្រាយពាក្យបណ្តឹងជាផ្លូវការដែលបានរៀបរាប់ជាលម្អិតនៅទីនេះ *MassDOT* នឹងចាត់វិធានការទប់ស្កាត់ការរើសអើង ដើម្បីស្វែងរកដំណោះស្រាយក្រៅផ្លូវការចំពោះពាក្យបណ្តឹងមាត្រាទី*6*ទាំងអស់នៅពេលណាដែលអាចធ្វើបាន។

**<u>ដំណើរការនៃការដាក់ពាក្យបណ្តឹង</u>**

**1. តើអ្នកណាអាចដាក់ពាក្យបណ្តឹងបាន?**

**គ្រប់**សាធារណជន រួមទាំងអតិថិជន បេក្ខជន ក្រុមហ៊ុនម៉ៅការ ឬ អ្នកទទួលជំនួយបន្តរបស់ MassDOT ទាំងអស់ដែលយល់ថា ពួកគេផ្ទាល់ ឬភាគីទីបី ឬក្រុមមនុស្សណាមួយត្រូវបានគេធ្វើបាប ឬមិនផ្តល់ភាពស្មើគ្នាដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត (រួមទាំង ចំណេះដឹងភាសាអង់គ្លេសមានកម្រិត) ដែលល្មើសនឹងមាត្រាទី*6* នៃច្បាប់ស្តីពីសិទ្ធស៊ីវិលឆ្នាំ*1964* ទាក់ទិននឹងដីការ និងច្បាប់រដ្ឋ និងសហព័ន្ធ ឬល្មើសនឹងគោលការណ៍ទប់ស្កាត់ការបំពានភាពគ្មានរើសអើងរបស់ *MassDOT (ADHP)*។ ការសងសឹកសាធារណជន ក្រោមហេតុផល ជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត ក៏ត្រូវបានហាមឃាត់ក្នុងមាត្រាទី*6* នឹង គោលការណ៍*ADHP*។

**2. តើខ្ញុំដាក់ពាក្យបណ្តឹងដោយរបៀបណា?**

ពាក្យបណ្តឹងអាចដាក់បានតាមរយៈ ៖

**Boston Region Metropolitan Planning Organization Title VI Specialist**
Email: eharvey@ctps.org
Phone: 857-702-3700

**អ្នកជំនាញមាត្រាទី6 របស់ MassDOT**

**(The MassDOT Title VI Specialist)**
ការិយាល័យសិទ្ធស៊ីវិលនិងចម្រុះរបស់ MassDOT

(MassDOT Office of Diversity and Civil Rights)
ទូរស័ព្ទ៖ 857-368-8580 ឬ 7-1-1 សេវាកម្មសម្រាប់ជនពិការ

អ៊ីម៉េល៖ MassDOT.CivilRights@state.ma.us

**ការិយាល័យសិទ្ធស៊ីវិលនិងចម្រុះរបស់ MassDOT–អង្គភាពស៊ើបអង្កេត**

**(The MassDOT Office of Diversity and Civil Rights- Investigations Unit)**
ជំនួយការលេខានៃការិយាល័យសិទ្ធស៊ីវិលនិងចម្រុះ MassDOT

(Assistant Secretary of Diversity & Civil Rights, MassDOT)
អ៊ីម៉េល៖ odcrcomplaints@dot.state.ma.us

**រដ្ឋបាលផ្លូវធំរបស់សហព័ន្ធ**

**(The Federal Highway Administration)**
រដ្ឋបាលផ្លូវធំរបស់សហព័ន្ធ

(Federal Highway Administration)
នាយកដ្ឋានដឹកជញ្ជូនសហរដ្ឋអាមេរិក

(U.S. Department of Transportation)
ការិយាល័យសិទ្ធស៊ីវិល

(Office of Civil Rights)
អ៊ីម៉េល៖ CivilRights.FHWA@dot.gov

ទូរស័ព្ទ៖ 202-366-0693

**រដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ**

**(*The Federal Transit Administration)***
រដ្ឋបាលសេវាធ្វើដំណើរសាធារណៈរបស់សហព័ន្ធ

***(Federal Transit Administration)***
នាយកដ្ឋានដឹកជញ្ជូនសហរដ្ឋអាមេរិក

(U.S. Department of Transportation)
ការិយាល័យសិទ្ធស៊ីវិល

(Office of Civil Rights)
ជូនចំពោះ៖ ក្រុមទទួលពាក្យបណ្តឹង

(Attention: Complaint Team)

សូមកំណត់ចំណាំថា៖

- នៅពេល *FTA* ទទួលពាក្យបណ្តឹងមាត្រាទី*6* ទាក់ទងនឹង *MassDOT* អ្នកទទួលជំនួយបន្ត ឬក្រុមហ៊ុនម៉ៅការ នោះ*FTA* អាចស្នើ *MassDOT* អោយស៊ើបអង្កេតករណីនេះ។
- ប្រសិនបើពាក្យបណ្តឹងមាត្រាទី*6* ត្រូវបានដាក់ទៅអោយ *MassDOT* ដោយចោទអង្គភាពផ្នែកផ្លូវធំរបស់ *MassDOT (MassDOT's Highway Division)*ពីបទបំពាន នោះពាក្យបណ្តឹងនឹងត្រូវបញ្ជូនបន្តទៅ ការិយាល័យផ្នែក *FHWA* ប្រចាំតំបន់ដែលនឹងបញ្ជូនពាក្យបណ្តឹងបន្តទៅការិយាល័យកណ្តាលផ្នែកសិទ្ធស៊ីវិលរបស់ *FHWA* សម្រាប់ចាត់ការបន្ត។
- ប្រសិនបើពាក្យបណ្តឹងមាត្រាទី*6* ប្តឹងអ្នកទទួលជំនួយបន្តរបស់អង្គភាពផ្នែកផ្លូវធំរបស់*MassDot* ហើយពាក្យបណ្តឹងត្រូវបានទទួលដោយ *MassDOT* នោះ *MassDOT* អាចចាត់ចែង និងស៊ើបអង្កេតពាក្យបណ្តឹង ឬ អាចនឹងបញ្ជូនបន្តទៅ *HCR* ដើម្បីស៊ើបអង្កេត។

## *3.* តើខ្ញុំត្រូវមានអ្វីខ្លះនៅក្នុងពាក្យបណ្តឹងរបស់ខ្ញុំ?

ទម្រង់បែបបទនៃពាក្យបណ្តឹងមាត្រាទី*6/*ភាពគ្មានការរើសអើង អាចទាញយកបានតាមរយៈប្រព័ន្ធអេឡិចត្រូនិច ពីគេហទំព័រមាត្រាទី*6*របស់*MassDOT* (http://www.massdot.state.ma.us/OfficeofCivilRights/TitleVI/FileAComplaint.aspx) ឬ ជាទម្រង់ក្រដាសបំពេញដោយដៃ ពីអ្នកជំនាញមាត្រាទី6 របស់MassDOT ដែលបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀត ដើមបណ្តឹងក៏អាចដាក់ពាក្យបណ្តឹងដែលមានលក្ខណៈស្រដៀងគ្នាក្នុងទម្រង់ផ្សេងទៀតដែលរួមមាន៖

- ឈ្មោះ ហត្ថលេខា និងព័ត៌មានទំនាក់ទំនងក្នុងពេលបច្ចុប្បន្នរបស់អ្នក (ដូចជាលេខទូរស័ព្ទ និងអាសយដ្ឋាន)
- ឈ្មោះ និងលេខសម្គាល់របស់ជនជាប់ចោទ (ប្រសិនបើអ្នកដឹង ហើយប្រសិនបើចាំបាច់)
- ការរៀបរាប់ពីពេលវេលា ទីកន្លែង និងវិធីដែលទង្វើហាមឃាត់ ដែលអ្នកកំពុងចោទប្តឹងនេះបានកើតឡើង
- ការរៀបរាប់លម្អិតថាតើហេតុអ្វីបានជាអ្នកយល់ថា គេប្រព្រឹត្តិទៅលើអ្នក ខុសពីអ្នកដទៃ?
- ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់សាក្សី ហើយនិង
- ព័ត៌មាននានាទាំងឡាយណាដែលអ្នកយល់ថាមានជាប់ទាក់ទងនឹងពាក្យបណ្តឹងរបស់អ្នក

ក. ក្នុងករណីដែលដើមបណ្តឹងមិនអាចផ្តល់លិខិតជាលាយលក្ខណ៍អក្សរបានទេ ពាក្យបណ្តឹងជាពាក្យសំដីអាចធ្វើទៅបានទៅកាន់ការិយាល័យសិទ្ធស៊ីវិល និងចម្រុះ (ODCR)។ ដើមបណ្តឹងនឹងត្រូវសម្ភាសដោយមន្ត្រីស៊ើបអង្កេតសិទ្ធស៊ីវិល (CRI)។ ប្រសិនបើចាំបាច់ មន្ត្រីCRI នឹងជួយដើមបណ្តឹងក្នុងការប្រែក្លាយពាក្យបណ្តឹងជាពាក្យសំដី មកជាពាក្យបណ្តឹងលាយលក្ខណ៍អក្សរ។ ដើមបណ្តឹងគួរតែចុះហត្ថលេខាលើគ្រប់ពាក្យបណ្តឹងទាំងអស់។

ខ. ពាក្យបណ្តឹងអនាមិកអាចនឹងដាក់តាមវិធីដូចគ្នា។ ពាក្យបណ្តឹងអនាមិកនឹងត្រូវបានស៊ើបអង្កេតតាមវិធីដូចគ្នានឹងពាក្យបណ្តឹងដទៃទៀត។

គ. ពាក្យបណ្តឹងសរសេរជាភាសាណាក៏ដោយដែលពិភពលោកទទួលស្គាល់ នឹងត្រូវបានគេទទួល។ អ្នកក៏អាចស្វែងរកបែបបទពាក្យបណ្តឹងជាពហុភាសាបានដែរ។

## 4. តើខ្ញុំត្រូវដាក់ពាក្យបណ្តឹងក្នុងរយៈពេលប៉ុន្មាន?

ក. ពាក្យបណ្តឹងចោទប្រកាន់ពីបទល្មើសមាត្រាទី6 និង/ឬ គោលការណ៍*ADHP*របស់*MassDOT* ត្រូវដាក់ មិនអោយលើសមួយរយប៉ែតសិបថ្ងៃ (***180***) ចាប់ពីថ្ងៃដែលបទល្មើសបានកើតឡើង។

ខ. ពាក្យបណ្តឹងចោទប្រកាន់ពីបទល្មើសច្បាប់រដ្ឋ ឬសហព័ន្ធ ត្រូវដាក់ក្នុងអំឡុងពេលដែលកំណត់ដោយបញ្ញត្តិ បទបញ្ជា ឬច្បាប់យុត្តិសាស្រ្ត។

## *5.* តើពាក្យបណ្តឹងរបស់ខ្ញុំនឹងត្រូវដោះស្រាយដោយរបៀបណា?

នៅពេលដែលពាក្យបណ្តឹងត្រូវបានទទួល ពាក្យបណ្តឹងនោះនឹងត្រូវបានប្រគល់អោយទៅមន្ត្រីស៊ើបអង្កេតសិទ្ធស៊ីវិល (*CRI*)។ មន្ត្រី*CRI*នេះនឹង៖

ក. កំណត់ដែនសមត្ថកិច្ច៖

ODCR មានដែនសមត្ថកិច្ច ប្រសិនបើពាក្យបណ្តឹង៖

1. ពាក់ព័ន្ធនឹងការអះអាង ឬ ការប្រព្រឹត្តិដែលរំលោភបំពាន៖
   - ការប្តេជ្ញាចិត្ត និង កាតព្វកិច្ចផ្លូវច្បាប់របស់MassDOTដើម្បីទប់ស្កាត់ការរើសអើង ការរំលោភបំពាន ឬ ការសងសឹក ដោយពឹងផ្អែកទៅលើលក្ខណៈការពារ ចំពោះផ្នែកណាមួយនៃសេវាកម្មផ្តល់ដោយភ្នាក់ងារជូនសាធារណជន។
   - ការប្តេជ្ញាចិត្តធ្វើឡើងដោយអ្នកទទួលជំនួយបន្ត និងក្រុមហ៊ុនម៉ៅការដែលកំពុងធ្វើការជាមួយ MassDOT ប្រកាន់ខ្ជាប់នឹងគោលការណ៍របស់ MassDOT ហើយ
2. ពាក្យបណ្តឹងនេះត្រូវបានដាក់ទាន់ពេលវេលា។

ខ. ជូនដំណឹងថាបានទទួលពាក្យបណ្តឹង ហើយផ្តល់សេចក្តីសម្រេចដែនសមត្ថកិច្ច ក្នុងរយៈពេល10ថ្ងៃធ្វើការ រាប់ចាប់ពីថ្ងៃទទួលពាក្យបណ្តឹងនេះ។

- ប្រសិនបើមន្ត្រីCRIសម្រេចថា ពាក្យបណ្តឹងមិនមានទាក់ទង់នឹងការបំពានសិទ្ធស៊ីវិល នោះមន្ត្រីCRI នឹងផ្តល់ដំណឹងទៅដើមបណ្តឹង និងអ្នកជំនាញមាត្រាទី6 ជាលាយលក្ខណ៍អក្សរពីលទ្ធផល ហើយករណីនោះនឹងត្រូវបានបញ្ចប់។

គ. ធ្វើការស៊ើបអង្កេតយ៉ាងល្អិតល្អន់លើការចោទប្រកាន់ដែលមាននៅក្នុងពាក្យបណ្តឹង ស្របទៅតាមនីតិវិធីនៃការដាក់ពាក្យបណ្តឹងផ្ទៃក្នុងរបស់ MassDOT។

## 6. លទ្ធផល និងការណែនាំ?

នៅទីបញ្ចប់នៃការស៊ើបអង្កេត មន្ត្រីCRI នឹងផ្ញើរលិខិតមួយ ក្នុងចំណោមលិខិតទាំងបីខាងក្រោមទៅអោយដើមបណ្ដឹង និងចុងបណ្ដឹងអាស្រ័យទៅលើលទ្ធផលនៃការស៊ើបអង្កេត៖

ក. លិខិតបញ្ជាក់ពីដំណោះស្រាយដែលពន្យល់ចុងបណ្ដឹងពីវិធានការដែលចុងបណ្ដឹងបានធ្វើ ឬនឹងត្រូវធ្វើ ដើម្បីអនុវត្តតាមមាត្រាទី6។

ខ. លិខិតបញ្ជាក់ពីលទ្ធផលថា ចុងបណ្ដឹងបានប្រព្រឹត្តត្រឹមត្រូវទៅតាមមាត្រាទី6។ លិខិតនេះនឹងមានការពន្យល់បកស្រាយពីហេតុផលដែលចុងបណ្ដឹងត្រូវបានរកឃើញថាគេបានប្រព្រឹត្តត្រឹមត្រូវ ហើយនិងផ្ដល់ព័ត៌មានទៅដើមបណ្ដឹងថាដើមបណ្ដឹងមានសិទ្ធប្ដឹងជំទាស់។

គ. លិខិតបញ្ជាក់ពីលទ្ធផលថា ចុងបណ្ដឹងត្រូវបានរកឃើញថាបានប្រព្រឹត្តខុស។ លិខិតនេះនឹងបញ្ជាក់ពីបទល្មើសនីមួយៗ ដោយយោងទៅតាមបទបញ្ញាដែលកំពុងដាក់អោយប្រើប្រាស់ ការរៀបរាប់សង្ខេបអំពីលទ្ធផល/ការណែនាំ ផលវិបាកនៃការមិនបានបំពេញការប្រព្រឹត្តតាមច្បាប់ដោយស្ម័គ្រចិត្ត ហើយនិងសំណើរផ្ដល់ជំនួយក្នុងការរៀបចំផែនការអនុលោមតាមច្បាប់ ប្រសិនបើសមស្រប។

## 7. តើខ្ញុំអាចប្ដឹងជំទាស់លទ្ធផលបានទេ?

ប្រសិនបើដើមបណ្ដឹង ឬ ចុងបណ្ដឹងមិនយល់ស្របនឹងការរកឃើញរបស់មន្ត្រី*CRI*ទេ គេអាចប្ដឹងជំទាស់ទៅជំនួយការលេខាធិការនៃការិយាល័យសិទ្ធស៊ីវិលនិងចម្រុះ។ ភាគីប្ដឹងជំទាស់ត្រូវតែផ្ដល់**ព័ត៌មានថ្មីណាមួយដែលមិនមានក្នុងអំឡុងពេលស៊ើបអង្កេតដំបូងដែលនឹងធ្វើអោយ MassDOT ពិចារណាលើការសម្រេចរបស់ខ្លួនសារជាថ្មីម្ដងទៀត។** ពាក្យស្នើប្ដឹងជំទាស់ និងព័ត៌មានថ្មីទាំងឡាយត្រូវតែដាក់បញ្ជូនមកក្នុងរយៈពេល 6០ ថ្ងៃ រាប់ចាប់ពីថ្ងៃដែលលិខិតបញ្ជាក់លទ្ធផលបានបញ្ជូនចេញទៅ។ បន្ទាប់ពីធ្វើការពិនិត្យសើរើព័ត៌មាននេះ MassDOT នឹងឆ្លើយតប ដោយចេញលិខិតបញ្ជាក់ដំណោះស្រាយដែលពួកគេបានកែសម្រួល ឬ ផ្ដល់ដំណឹងទៅភាគីប្ដឹងជំទាស់ថា លិខិតបញ្ជាក់ពីដំណោះស្រាយ ឬលិខិតបញ្ជាក់ពីលទ្ធផលច្បាប់ដើមនៅតែមានប្រសិទ្ធភាព។